雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.153

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7640 ថ្ងៃសុក្រ ទី 25 ខែ ឧសភា ឆ្នាំ 2018

## អង្គការសង្គមស៊ីវិលចិន និងកម្ពុជាពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស្អិតល្មួត



*ទិដ្ឋភាពនៃកិច្ចប្រជុំរវាង អង្គការសង្គមស៊ីវិលចិន និងកម្ពុជា (រូបថតដោយ Yu Jiangning )*

នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ សមាគមជំរុញទំនាក់ទំនងអន្តរជាតិនៃអង្គការសង្គមស៊ីវិលចិន មូលនិធិដើម្បីសន្តិភាពនិងអភិវឌ្ឍន៍របស់ប្រទេសចិន ព្រមទាំងអង្គការសង្គមស៊ីវិលចិនចំនួន ២០និងអង្គការសង្គមស៊ីវិលកម្ពុជាចំនួន២៨ បានរៀបចំកិច្ចប្រជុំផ្លាស់ប្តូរនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិគ្រោះពិភាក្សាអំពីដំណោះស្រាយបញ្ហាប្រឈមផ្សេងៗលើវិស័យអប់រំ និងសុខាភិបាលជាដើម។ អង្គប្រជុំបានឯកភាពគ្នាលើកិច្ចសហប្រតិបត្តិការក្នុងវិស័យពាក់ព័ន្ធផ្សេងៗ រួមមាន ការកាត់បន្ថយភាពក្រីក្រ ការអប់រំ ការថែរក្សាការពារបរិស្ថាន បច្ចេកទេសវិទ្យាសាស្ត្រ ការកម្ចាត់មីន និងវិស័យសុខាភិបាលជាដើម ។

លោកលីវ ខាយយ៉ាង អគ្គលេខាធិការរងសមាគមជំរុញទំនាក់ទំនងអន្តរជាតិនៃអង្គការសង្គមស៊ីវិលចិនបានមានប្រសាសន៍ថា សព្វថ្ងៃមានអង្គការសង្គមស៊ីវិលចិនកាន់តែច្រើនមានបំណងចង់បង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលកម្ពុជា ដើម្បីធ្វើបទឧទ្ទេសនាម និងចែករំលែកគ្នាជាមួយសហការីកម្ពុជាអំពីក្តីបំណងដ៏ល្អបវរ គំនិតសប្បុរសធម៌និងទស្សនទានអំពីការអភិវឌ្ឍន៍របស់ប្រជាជនចិន ។ អង្គការសង្គមស៊ីវិលចិននឹងរួមចំណែកកាន់តែច្រើនក្នុងការអភិវឌ្ឍសង្គមកម្ពុជា និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរ ដើម្បីជំរុញការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិលរវាងប្រទេសទាំងពីរនិងធ្វើឱ្យប្រជាជននៃប្រទេសទាំងពីរមានទំនាក់ទំនងកាន់តែជិតស្និទ្ធ។

លោក គឹមរ័ត្ន វិសិដ្ឋ ប្រធានក្រុមប្រឹក្សាភិបាលវេទិកាសម្ព័ន្ធសង្គមស៊ីវិលកម្ពុជា បានមានប្រសាសន៍ថា កិច្ចប្រជុំផ្លាស់ប្តូររវាងអង្គការសង្គមស៊ីវិលកម្ពុជានិងចិននេះបានបង្កើតវេទិកាដ៏ល្អ និងសំខាន់មួយសម្រាប់បង្កើនការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិលនៃប្រទេសទាំងពីរ និងបាននាំមកនូវកាលានុវត្តភាពថ្មី ។ ភាគីទាំងពីរកម្ពុជា និងចិននឹងពិគ្រោះពិភាក្សាអំពីដំណោះស្រាយបញ្ហាប្រឈមមួយចំនួនដែលមានពាក់ព័ន្ធទៅនឹងគម្រោងផ្សេងៗ ដោយឈរលើគោលការណ៍មេត្រីភាព និងសហប្រតិបត្តិការ ដើម្បីបង្កើនការយល់ដឹងគ្នា និងជំរុញការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅថែមទៀត ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ប៉ុន្មានឆ្នាំនេះ អង្គការសង្គមស៊ីវិលចិនដែលជាសមាជិកនៃសមាគមជំរុញទំនាក់ទំនងអន្តរជាតិនៃអង្គការសង្គមស៊ីវិលចិន និងមូលនិធិដើម្បីសន្តិភាពនិងអភិវឌ្ឍន៍របស់ប្រទេសចិន បានរៀបចំនិងអនុវត្តន៍គម្រោងសប្បុរសធម៌ជាច្រើននៅប្រទេសកម្ពុជា រួមមានការសាងសង់សាលារៀន មជ្ឈមណ្ឌលសុខភាព និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៅតាមតំបន់ផ្សេងៗក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺជាដើម ៕

**ដោយ យូ ជាំងនីង និង ឌឹង ហ៊ឹង**

## ខេត្តព្រះវិហារនៃប្រទេសកម្ពុជា និងក្រុងលីជាំង ខេត្តយូនណានប្រទេសចិនចងសម្ព័ន្ធមេត្រីភាព




*ក្រុងលីជាំងខេត្តយូនណាន ប្រទេសចិន និងខេត្តព្រះវិហារនៃ ប្រទេសកម្ពុជា បានចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការចងសម្ព័ន្ធមេត្រីភាពអន្តរជាតិ (រូបថតដោយ Zhou Shijing )*

នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០១៨ ក្រុងលីជាំងខេត្តយូនណាន ប្រទេសចិន និងខេត្តព្រះវិហារនៃប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការចងសម្ព័ន្ធមេត្រីភាពអន្តរជាតិ ។ ភាគីទាំងពីរនឹងរួមគ្នាបង្កើនការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ និងការការពារបេតិកភណ្ឌវប្បធម៌ពិភពលោកជាដើម ។

អ្នកទទួលខុសត្រូវពាក់ព័ន្ធនៃក្រុងលីជាំងបានបញ្ជាក់ថា ប្រទេសទាំងពីរចិន និងកម្ពុជាមានមិត្តភាពដ៏ជ្រាលជ្រៅ ។ ក្រុងលីជាំង និងខេត្តព្រះវិហារសុទ្ធតែជាកន្លែងដែលមានបេតិកភណ្ឌវប្បធម៌ពិភពលោក ហើយមានចំណុចដូចគ្នាជាច្រើនក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ និងការអភិវឌ្ឍធនធានជីវសាស្ត្រជាដើម ។ ដូច្នេះភាគីទាំងពីរអាចមានចន្លោះទូលំទូលាយក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ ។ ភាគីលីជាំងសង្ឃឹមថា ភាគីទាំងពីរនឹងអាចជំរុញកិច្ចសហប្រតិបត្តិការគ្រប់រូបភាព និងគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើឱ្យទំនាក់ទំនងសម្ព័ន្ធមេត្រីភាពរវាងភាគីទាំងពីរទទួលបាននូវលទ្ធផលជាផ្លែផ្កាកាន់តែច្រើនឡើងៗ ។ អ្នកទទួលខុសត្រូវនៃខេត្តព្រះវិហារបានថ្លែងថា ក្រុងលីជាំងជាក្រុងដ៏ស្អាតមួយ ដែលមានលក្ខណៈបើកទូលាយ និងមានអរិយធម៌ត្រចះត្រចង់ ។ ខេត្តព្រះវិហារសង្ឃឹមថា តាមរយៈការចងសម្ព័ន្ធមេត្រីភាពរវាងភាគីទាំងពីរ ប្រជាជននៃខេត្តព្រះវិហារ និងក្រុងលីជាំងនឹងអាចទទួលបាននូវផលប្រយោជន៍ជាក់ស្តែងកាន់តែច្រើន និងពង្រឹងចំណងមិត្តភាពរវាង ប្រទេសទាំងពីរចិន និងកម្ពុជា ៕

**ដោយ លីវ យ៉ុង**

## កម្មវិធី "ដំណើរពន្លឺរស្មីឡានឆាង-មេគង្គ" រួមចំណែកក្នុងការថែរក្សាសុខភាពភ្នែករបស់សិស្សខ្មែរ

ក្នុងអំឡុងពេលពីថ្ងៃទី ៦ ដល់ទី១៣ ខែឧសភា ឆ្នាំ២០១៨ កម្មវិធី "ដំណើរពន្លឺរស្មីឡានឆាង-មេគង្គ" ដែលផ្តួចផ្តើមដោយសមាគមទំនាក់ទំនងការទូតសាធារណៈចិន និងរៀបចំដោយមូលនិធិសប្បុរសធម៌អាណិកជនចិន មូលនិធិសប្បុរសធម៌ស្រឡាញ់ភ្នែក និងមន្ទីរពេទ្យព្យាបាលចក្ខុរោគ AIER បានត្រូវរៀបចំនៅប្រទេសកម្ពុជា ដើម្បីជួយពិនិត្យសុខភាពភ្នែករបស់សិស្សមធ្យមសិក្សា និងបឋមសិក្សាខ្មែរ និងផ្តល់យោបល់ជំនាញសម្រាប់ថែរក្សាសុខភាពភ្នែករបស់សិស្សានុសិស្សនៅសាលារៀនផ្សេងៗក្នុងប្រទេសកម្ពុជា ។



*លោកវេជ្ជបណ្ឌិតចិនមួយរូប កំពុងត្រួតពិនិត្យភ្នែកជូននិស្សិតកម្ពុជា មួយរូប (រូបថតដោយ Yu Jiangning )*

លោក លីវ ពីវៃ អនុប្រធានសមាគមទំនាក់ទំនងការទូតសាធារណៈចិនបានមានប្រសាសន៍ថា ក្នុងឱកាសកម្មភាពនេះ គ្រូពេទ្យជំនាញផ្នែកចក្ខុរោគរបស់ប្រទេសចិននឹងអញ្ជើញទៅជួយពិនិត្យសុខភាពភ្នែករបស់សិស្សានុសិស្សនៅសាលារៀនចំនួន៤ ក្នុងរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ។ ក្រៅពីនេះ គ្រូពេទ្យចិននឹងជួយផលិត និងផ្តល់វ៉ែនតាមីញ៉ូបឱ្យសិស្សភ្នែកមីញ៉ូបដោយឥតគិតថ្លៃ ។

គួរបញ្ជាក់ថា នៅពេលដំបូង កម្មវិធី "ដំណើរពន្លឺរស្មីឡានឆាង-មេគង្គ"នេះ មានឈ្មោះថា"ដំណើរពន្លឺរស្មីទន្លេមេគង្គ" ។ គម្រោងនេះបានត្រូវដាក់បញ្ចូលក្នុងបញ្ជីឈ្មោះនៃគម្រោងអាទិភាពក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំនៃកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គនៅឆ្នាំ២០១៦ ។ ក្នុងគម្រោងដំណាក់កាលទី ១ សមាគមទំនាក់ទំនងការទូតសាធារណៈចិនបានរៀបចំឱ្យមន្ទីរពេទ្យព្យាបាលចក្ខុរោគ AIER និងមជ្ឈមណ្ឌលចក្ខុរោគនៃសកលវិទ្យាល័យស្យាមិនជួយធ្វើការវះកាត់ដោយឥតគិតថ្លៃឱ្យអ្នកមានជំងឺភ្នែកឡើងបាយនៅប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលបានធ្វើឱ្យអ្នកជំងឺប្រមាណ ៨០០ នាក់អាចមើលឃើញពិភពលោកយ៉ាងច្បាស់លាស់ជាថ្មីឡើងវិញ ។ គម្រោងដំណាក់កាលទី ២ នឹងត្រូវរៀបចំនិងអនុវត្តន៍នៅប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម សម្រាប់ជួយពិនិត្យសុខភាពភ្នែកនិងផ្តល់វ៉ែនតាមីញ៉ូបដល់សិស្សមធ្យមសិក្សា និងបឋមសិក្សាប្រមាណមួយម៉ឺននាក់ ៕

**ដោយ ម៉ាវ ភីងហ្វី (ស៊ីនហួចិន)**

## ខេត្តយូនណានឋានសួគ៌ថតរូបទេសចរណ៍ពិសេស

លោក ហ្វាង តាស្យេង ស្ថាបនិកនៃសមាគមអ្នកថតរូបទេសចរណ៍ខេត្តយូនណាន បានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថា ខេត្តយូនណានសម្បូរទៅដោយធនធានទេសចរណ៍ដ៏ចម្រុះពណ៌ ដែលបានធ្វើឱ្យយូនណានក្លាយទៅជាឋានសួគ៌សម្រាប់ថតរូបមួយ ។ លោកបានបញ្ជាក់ថា ខេត្តយូនណានមានទេសភាពធម្មជាតិដ៏ស្រស់ស្អាត និងមានទំនៀមទម្លាប់ប្រពៃណីជនជាតិភាគតិចដ៏វិសេសវិសាល ដែលបានទាក់ទាញឱ្យអ្នកទេសចរ និងអ្នកនិយមថតរូបកាន់តែច្រើនមកដើរលេងខេត្តយូនណាន ។

ប៉ុន្មានឆ្នាំនេះ ទេសចរដែលមកថតរូប និងដើរលេងនៅខេត្តយូនណានមានចំនួនកាន់តែច្រើនឡើងៗ ។ លោកបានបន្តទៀតថា រមណីយដ្ឋានទេសចរណ៍ថ្មីជាច្រើននៅខេត្តយូនណានបានត្រូវរកឃើញដោយអ្នកនិយមថតរូប ។ ឧទាហរណ៍ តំបន់ដីក្រហមតុងឈួន ស្រែរាងជណ្តើរយាន់យ៉ាង និងចម្ការសមុទ្រផ្កាស្រុកលួភីងជាដើម សុទ្ធតែជារមណីយដ្ឋានទេសចរណ៍ល្បីឈ្មោះទាំងក្នុង និងក្រៅប្រទេសចិន ។ អ្នកថតរូបបានប្រើប្រាស់កាមេរ៉ារបស់ពួកគាត់សម្រាប់កត់ត្រានូវសម្រស់ស្អាតដ៏ទាក់ទាញរបស់ខេត្តយូនណាន និងបានផ្សព្វផ្សាយអំពីទេសភាពខេត្តយូនណានតាមរយៈរូបថតល្អៗដែលបានទាក់ទាញឱ្យទេសចរជាតិ និងអន្តរជាតិកាន់តែច្រើនមកដើរលេងនៅខេត្តយូនណាន ។

ម្យ៉ាងទៀត អ្នកថតរូបជាច្រើនក៏បានចាប់អារម្មណ៍ចំពោះធនធានសត្វព្រៃដ៏សម្បូរនៅខេត្តយូនណាន ដែរ ។ លោក ស៊ុន សៀវហុង អ្នកថតរូបធម្មជាតិម្នាក់បានជាប់ចិត្តយ៉ាងខ្លាំងទៅនឹងធនធានសត្វព្រៃនៅខេត្តយូនណាន។នៅដើមខែឧសភា លោកបានធ្វើដំណើរពីក្រុងប៉េកាំងមកដល់ឃុំណាប៉ាង ស្រុកយីងជាំងខេត្តយូនណានដើម្បីមកថតរូបសត្វស្លាបពីរប្រភេទ ដែល ទើបត្រូវគេរកឃើញជាថ្មី ។ ចំណែកអ្នកភូមិតាមតំបន់ក៏បានទទួលផលប្រយោជន៍ជាក់ស្តែងជាច្រើនផងដែរ ។ ក្នុងអំឡុង ពេលប៉ុន្មានឆ្នាំកន្លងទៅនោះអ្នកភូមិក្នុងស្រុកយីងជាំងបានបង្កើនចំណូលរបស់ខ្លួនពី២.០០០យ័នដល់ទៅ៣ម៉ឺនយ័នក្នុងមួយឆ្នាំតាមរយៈការអភិវឌ្ឍវិស័យអេកូទេសចរណ៍និងការទាក់ទាញឱ្យភ្ញៀវទេសចរមកថតរូប៕ **ដោយ ឈឺន ឈ្លួងយី**

## ពិធីប្រគល់ និងផ្ទេររថយន្តពេទ្យដែលជាជំនួយរបស់ប្រទេសចិនប្រារព្ធនៅរាជធានីភ្នំពេញ

ព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៨ ពិធីប្រគល់និងផ្ទេររថយន្តពេទ្យ២០គ្រឿង ដែលជាជំនួយក្រុមទី ១ តាមគម្រោង"គ្លីនិកចល័ត"ដែលរដ្ឋាភិបាលចិនផ្តល់ជំនួយដល់ប្រទេសកម្ពុជា នោះបានប្រារព្ធនៅរាជធានីភ្នំពេញ ។

ក្នុងពិធីនេះ រថយន្តពេទ្យទំនើបថ្មីទាំងនោះបានទាក់ទាញឱ្យមន្ត្រីរាជការ និងគ្រូពេទ្យខ្មែរច្រើនមកទស្សនា ។ រថយន្តពេទ្យពណ៌សនេះមានប្រវែង១២ម៉ែត្រ ហើយមានផ្ទិតរូបទង់ជាតិចិន និងកម្ពុជា ដែលអាចទាក់ទាញក្រសែភ្នែករបស់គេ ។ ដើម្បីបំពេញតម្រូវការជាក់ស្តែងផ្នែកអាកាសធាតុនៃប្រទេសកម្ពុជា រថយន្តពេទ្យនេះបានត្រូវបំពាក់ដោយតង់ និងកៅអីដែលអាចបត់បាន សម្រាប់ផ្តល់ការងាយស្រួលដល់ការពិនិត្យសុខភាព និងព្យាបាលជំងឺ ។ តាមការឧទ្ទេសនាមពីការិយាល័យពាណិជ្ជកម្មនៃស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាបានឱ្យដឹងថា រថយន្តពេទ្យទាំងនេះនឹងអាចបំពេញតម្រូវការផ្នែកសុខាភិបាលរបស់ប្រទេសកម្ពុជា រួមមានការព្យាបាលជំងឺកុមារ ជំងឺទូទៅ ជំងឺស្ត្រី ផ្នែកសម្ភព ទន្តទេព្យ ជំងឺត្រចៀក ច្រមុះ និងបំពង់ក ព្រមទាំងការថតរស្មី X និងការពិនិត្យ ultrasonic ជាដើម ។

គួរបញ្ជាក់ថា តាមរយៈគម្រោង "គ្លីនិកចល័ត" នេះ ប្រទេសចិនផ្តល់ជំនួយជារថយន្តពេទ្យ៤០គ្រឿងដល់ប្រទេសកម្ពុជា ចំណែករថយន្តនៅសល់នឹងត្រូវដឹកជញ្ជូនទៅដល់ប្រទេសកម្ពុជាមុននឹងចុងខែតុលាឆ្នាំនេះ ។ ដល់ពេលនោះ រាធានីភ្នំពេញ និងខេត្តចំនួន២៤ នៃប្រទេសកម្ពុជាសុទ្ធតែនឹងអាចមាន "គ្លីនិកចល័ត" ទំនើបនេះ ។ ក្រៅពីនេះគ្រូពេទ្យជំនាញចិននឹងទៅប្រទេសកម្ពុជាក្នុងពេលជិតៗ ដើម្បីផ្តល់សេវាកម្មសុខាភិបាលដល់ប្រជាជនកម្ពុជាតាមរថយន្តពេទ្យទាំងនេះ ។ នេះនឹងអាចធ្វើឱ្យរថយន្តពេទ្យដែលជាជំនួយរបស់ប្រទេសចិននោះដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍវិស័យសុខាភិបាលនៃប្រទេសកម្ពុជា ៕

**ដោយ ម៉ាវ ភីងហ្វី (ស៊ីនហួ ចិន)**